ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៣២៧ ប្រក.កសក

មកដល់លេខ ...1480... រ.ក
ចុះថ្ងៃទី ...30.5.2017...
ម៉ោង ......

# ប្រកាស
# ស្តីពី
# វិធានព្រៃឯកជន

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការប្តូរឈ្មោះនាយកដ្ឋានរុក្ខាប្រមាញ់ទៅជារដ្ឋបាលព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកេស្រ្តសាស្រ្តនិងកែលម្អដីកសិកម្ម ឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៥៣ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីនីតិវិធី ការបង្កើត ការចាត់ថ្នាក់ និងការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍
- បានឃើញអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៨ ស្តីពីវិធាននៃការផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ការដាំឈើ
- បានឃើញអនុក្រឹត្យលេខ៣៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា

- បានឃើញប្រកាសលេខ៥០៩ ប្រក.កសក.ប ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ
- បានឃើញប្រកាសលេខ៦០២ ប្រក.កសក.ប ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ និងអង្គភាពចំណុះនាយកដ្ឋាន វិទ្យាស្ថាន និងឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ នៃរដ្ឋបាលព្រៃឈើ
- បានឃើញប្រកាសលេខ៣៥៦ ប្រក.កសក.ប ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលប្រកាសលេខ៥០៩ ប្រក.កសក.ប ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ
- បានឃើញប្រកាសលេខ៦០៩ ប្រក.កសក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការប្តូរឈ្មោះមន្ទីរកសិកម្ម រាជធានី ខេត្ត និងការដាក់បញ្ចូលខណ្ឌរដ្ឋបាលព្រៃឈើ និងខណ្ឌរដ្ឋបាលជលផលឲ្យស្ថិតនៅក្រោមមន្ទីរកសិកម្ម រាជធានី ខេត្ត
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១._**

ប្រកាសនេះមានគោលបំណងកំណត់នូវវិធានព្រៃឯកជន សម្រាប់ជាគោលការណ៍ណែនាំក្នុងការបង្កើត និងការអភិវឌ្ឍព្រៃឯកជន នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២._**

ប្រកាសនេះមានគោលដៅ៖

-ជំរុញ និងលើកទឹកចិត្តដល់រូបវន្តបុគ្គលឬនីតិបុគ្គលឯកជនដែលជាកម្មសិទ្ធិករដីធ្លី ក្នុងការចូលរួមដាំដុះឈើលើដីកម្មសិទ្ធិឯកជន ដើម្បីបង្កើតព្រៃឯកជន អភិវឌ្ឍគម្របព្រៃដាំ និងបង្កើនប្រភពផ្គត់ផ្គង់ផល អនុផលព្រៃឈើចេញពីចម្ការព្រៃដាំសម្រាប់កែច្នៃ ប្រើប្រាស់ក្នុងស្រុក និងនាំចេញ

-លើកកម្ពស់ការយល់ដឹងជាសាធារណៈស្តីពីសារៈប្រយោជន៍នៃចម្ការព្រៃដាំ និងសក្តានុពលនៃចម្ការព្រៃដាំឯកជនក្នុងការលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋាន ព្រមទាំងចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងការគាំពារបរិស្ថាន

-ភ្ជាប់ទំនាក់ទំនងរវាងរូបវន្តបុគ្គលឬនីតិបុគ្គលឯកជន ដែលជាកម្មសិទ្ធិករដីធ្លីជាមួយរដ្ឋបាលព្រៃឈើតាមរយៈការបង្កើត និងការអភិវឌ្ឍចម្ការព្រៃដាំឯកជន។

**ប្រការ៣._**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រប់ចម្ការព្រៃដាំដោយឯកជននៅលើដីកម្មសិទ្ធិឯកជន ដែលទទួលសិទ្ធិកាន់កាប់ស្របតាមច្បាប់ភូមិបាល។

ចម្ការព្រៃដាំដោយឯកជនដែលបានបង្កើតឡើងតាមរយៈការផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋ ត្រូវស្ថិតនៅក្រោមវិសាលភាពនៃអនុក្រឹត្យដោយឡែក។

**ប្រការ៤._**

វាក្យសព្ទសំខាន់ដែលប្រើក្រោមគោលបំណងនៃប្រកាសនេះ មាននិយមន័យដូចខាងក្រោម៖



ហ.

១-ព្រៃឯកជនៈ សំដៅដល់ចម្ការព្រៃដាំដែលបានបង្កើតឡើង ដោយរូបវន្តបុគ្គលឬនីតិបុគ្គលឯកជនដែលជាកម្មសិទ្ធិករដីធ្លីនៅលើដីកម្មសិទ្ធិឯកជនរបស់ខ្លួន ដែលបានទទួលសិទ្ធិកាន់កាប់ស្របតាមច្បាប់ភូមិបាល និងត្រូវបានចុះបញ្ជីទទួលស្គាល់ជាព្រៃឯកជនស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីព្រៃឈើ និងប្រកាសនេះ។

មិនត្រូវបានចាត់ទុកជាព្រៃឯកជន ចំពោះចម្ការព្រៃដាំទាំងឡាយណាដែលបានបង្កើតឡើង នៅលើដីដែលកាន់កាប់ដោយរំលោភផ្ទុយពីច្បាប់ភូមិបាល ឬនៅលើដីដែលបានមកពីការកាប់រាន និងកាន់កាប់ដីព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ដែលផ្ទុយនឹងច្បាប់ស្តីពីព្រៃឈើ។

២-រូបវន្តបុគ្គលឬនីតិបុគ្គលឯកជនៈ សំដៅដល់ផ្នែកឯកជន សហគមន៍ ប្រជាពលរដ្ឋ បុគ្គល ជាលក្ខណៈគ្រួសារ ឬឯកត្តជន ។

៣-ប្រភេទឈើរាតត្បាតឬប្រភេទចំណូលថ្មីឈ្លានពានៈ សំដៅដល់បណ្តាប្រភេទ អំបូរសម្ព័ន្ធ ឬអង្គបន្តពូជរុក្ខជាតិ ដែលបាននាំចូលមកក្នុងលំនៅដ្ឋានឬមជ្ឈដ្ឋានថ្មី ក្រៅដែនរបាយធម្មតារបស់វា ក្នុងអតីតកាលឬបច្ចុប្បន្ន ដោយបានបង្កភាពប្រែប្រួល និងវិវត្តន៍នៅក្នុងលក្ខខណ្ឌនៃប្រព័ន្ធមជ្ឈដ្ឋានថ្មី ធម្មជាតិ ពាក់កណ្តាលធម្មជាតិ ឬសិប្បនិម្មិត (ប្រព័ន្ធមជ្ឈដ្ឋានព្រៃដាំ) និងបានរាលដាលគ្របដណ្តប់ ឬរាតត្បាត និងគំរាមកំហែងដល់ជីវចម្រុះដើមកំណើត។

៤-បច្ចេកទេសរុក្ខវប្បកម្មៈ សំដៅដល់បណ្តាអន្តរាគមន៍បច្ចេកទេស ឬការធ្វើប្រព្រឹត្តកម្ម ដែលត្រូវអនុវត្តចំពោះចម្ការព្រៃដាំ ចាប់ពីដំណាក់កាលដំណុះព្រៃពេញវ័យ រហូតដល់អាយុប្រមូលផល ដើម្បីបំពេញគោលបំណងក្នុងការគ្រប់គ្រងចម្ការព្រៃដាំតាមរយៈអន្តរាគមន៍បច្ចេកទេស ជំរុញការលូតលាស់របស់ដំណុះព្រៃ បង្កើនគុណភាព និងទិន្នផលនៃដំណុះព្រៃ។

## ជំពូកទី២
## ការបង្កើត និងការចុះបញ្ជីព្រៃឯកជន

### ប្រការ៥._

រូបវន្តបុគ្គលឬនីតិបុគ្គលឯកជនដែលជាកម្មសិទ្ធិករដីធ្លី ដែលបង្កើតព្រៃឯកជន ត្រូវស្នើសុំចុះបញ្ជីព្រៃឯកជនរបស់ខ្លួន ដើម្បីទទួលបាននូវផលប្រយោជន៍ដូចខាងក្រោម៖

-ទទួលបាននូវការតម្រង់ទិសការងារបច្ចេកទេសជាមុន ដោយរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ដើម្បីជៀសវាងការបង់ខាតនៅក្នុងដំណើរការបង្កើតព្រៃឯកជន

-ទទួលបាននូវសេវាកម្មបណ្តុះបណ្តាលជំនាញបច្ចេកទេសដាំឈើ និងការគ្រប់គ្រងចម្ការព្រៃដាំ ដោយមិនបង់កម្រៃ ដែលផ្តល់ដោយរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច នៅមុនពេលចាប់ផ្តើមអនុវត្តដំណើរការដាំដុះឬបង្កើតព្រៃឯកជន

-ទទួលបាននូវការគាំទ្រសេវាបច្ចេកទេសដោយរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច នៅក្នុងដំណើរការបង្កើត ថែទាំ និងការប្រមូលផលព្រៃឯកជនរបស់ខ្លួន

-ត្រូវបានទទួលស្គាល់ជាផ្លូវការពីរដ្ឋបាលព្រៃឈើ ដែលអាចជួយសម្រួលដល់កម្មសិទ្ធិករឬសិទ្ធិវន្តនៃព្រៃឯកជន នៅពេលប្រមូលផល ការកែច្នៃ និងការធ្វើពាណិជ្ជកម្មផល អនុផលព្រៃឈើ ចេញពីព្រៃឯកជនរបស់ខ្លួន

-ទទួលបានការលើកទឹកចិត្តពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្របតាមច្បាប់ស្តីពីព្រៃឈើ។

### ប្រការ៦._

រដ្ឋបាលព្រៃឈើត្រូវរៀបចំ និងអនុវត្តកម្មវិធីផ្សព្វផ្សាយស្តីពីព្រៃឯកជន ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីសារៈប្រយោជន៍នៃការចូលរួមបង្កើតព្រៃឯកជន និងផ្តល់សេវាបណ្តុះបណ្តាលជំនាញបច្ចេកទេសដាំឈើនិងការគ្រប់គ្រងចម្ការព្រៃដាំ ចំពោះកម្មសិទ្ធិករដីធ្លីដែលមានបំណងបង្កើតព្រៃឯកជន។

កម្មវិធីសម្រាប់វគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសដាំឈើនិងការគ្រប់គ្រងចម្ការព្រៃដាំ ត្រូវកំណត់ដោយគោលការណ៍ណែនាំរបស់រដ្ឋបាលព្រៃឈើ។



M

**ប្រការ៧._**

ព្រៃឯកជនដែលស្នើសុំបង្កើត ត្រូវបានចាត់ថ្នាក់តាមទំហំ ដូចខាងក្រោម៖

១-ព្រៃឯកជនលក្ខណៈគ្រួសារ៖ ស្នើសុំបង្កើតលើផ្ទៃដីទំហំក្រោម១០(ដប់)ហិកតា ។

២-ព្រៃឯកជនទំហំតូច៖ ស្នើសុំបង្កើតលើផ្ទៃដីទំហំលើសពី១០(ដប់)-១០០(មួយរយ)ហិកតា។

៣-ព្រៃឯកជនទំហំមធ្យម៖ ស្នើសុំបង្កើតលើផ្ទៃដីទំហំលើសពី១០០ (មួយរយ)-១០០០ (មួយពាន់)ហិកតា។

៤-ព្រៃឯកជនទំហំធំ៖ ស្នើសុំបង្កើតលើផ្ទៃដីទំហំលើសពី១០០០(មួយពាន់)ហិកតា។

**ប្រការ៨._**

រូបវន្តបុគ្គលឬនីតិបុគ្គលឯកជនជាកម្មសិទ្ធិករដីធ្លី ដែលស្នើសុំចុះបញ្ជីព្រៃឯកជនរបស់ខ្លួន ត្រូវអនុវត្តតាមវិធានដូចខាងក្រោម៖

១-ព្រៃឯកជនលក្ខណៈគ្រួសារ៖ ត្រូវរាយការណ៍ ឬជូនដំណឹងជាលាយលក្ខណ៍អក្សរមកខណ្ឌរដ្ឋបាលព្រៃឈើ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្តសាមី អំពីការបង្កើតព្រៃឯកជនរបស់ខ្លួន ដោយភ្ជាប់ជាមួយនូវឯកសារបញ្ជាក់សិទ្ធិកាន់កាប់ដីធ្លី ប្លង់ទីតាំងដាំដុះឈើបង្កើតជាព្រៃឯកជន ប្រភេទឈើដាំ និងឯកសារពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់ ។

២-ព្រៃឯកជនទំហំតូច៖ ត្រូវស្នើសុំចុះបញ្ជីព្រៃឯកជនរបស់ខ្លួននៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្តសាមី ដោយភ្ជាប់ជាមួយនូវឯកសារបញ្ជាក់សិទ្ធិកាន់កាប់ដីធ្លី ប្លង់ទីតាំងដាំដុះឈើបង្កើតជាព្រៃឯកជន ព្រមទាំងផែនការដាំដុះបង្កើតព្រៃឯកជនរបស់ខ្លួន និងឯកសារពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់។

៣-ព្រៃឯកជនទំហំមធ្យម៖ ត្រូវស្នើសុំចុះបញ្ជីព្រៃឯកជនរបស់ខ្លួននៅរដ្ឋបាលព្រៃឈើ តាមរយៈមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្តសាមី ដោយភ្ជាប់មកជាមួយនូវឯកសារបញ្ជាក់សិទ្ធិកាន់កាប់ដីធ្លី ប្លង់ទីតាំងដាំដុះឈើបង្កើតជាព្រៃឯកជន ព្រមទាំងផែនការដាំដុះបង្កើតព្រៃឯកជនរបស់ខ្លួន និងឯកសារពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់។

៤-ព្រៃឯកជនទំហំធំ៖ ត្រូវស្នើសុំចុះបញ្ជីព្រៃឯកជនរបស់ខ្លួននៅរដ្ឋបាលព្រៃឈើ និងត្រូវសម្រេចដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយភ្ជាប់មកជាមួយនូវឯកសារបញ្ជាក់សិទ្ធិកាន់កាប់ដីធ្លី ប្លង់ទីតាំងដាំដុះឈើបង្កើតជាព្រៃឯកជន ព្រមទាំងផែនការអភិវឌ្ឍព្រៃឯកជនរបស់ខ្លួន និងឯកសារពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់។

**ប្រការ៩._**

រូបវន្តបុគ្គលឬនីតិបុគ្គលឯកជនជាកម្មសិទ្ធិករដីធ្លី ដែលស្នើសុំចុះបញ្ជីព្រៃឯកជនរបស់ខ្លួនអាចស្នើសុំកិច្ចសម្របសម្រួលនិងការគាំទ្រផ្នែកបច្ចេកទេសពីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច នៅក្នុងការរៀបចំផែនការដាំដុះបង្កើតព្រៃឯកជន និងផែនការអភិវឌ្ឍព្រៃឯកជន តាមការចាំបាច់។

រដ្ឋបាលព្រៃឈើត្រូវផ្តល់ការគាំទ្រជំនួយបច្ចេកទេសក្នុងការរៀបចំផែនការដាំដុះបង្កើតព្រៃឯកជន និងផែនការអភិវឌ្ឍព្រៃឯកជន តាមរយៈការផ្តល់សេវាកម្មវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសដាំឈើនិងការគ្រប់គ្រងចម្ការព្រៃដាំដល់កម្មសិទ្ធិករដីធ្លី។

គំរូផែនការដាំដុះបង្កើតព្រៃឯកជន និងផែនការអភិវឌ្ឍព្រៃឯកជន ត្រូវកំណត់ដោយគោលការណ៍ណែនាំរបស់រដ្ឋបាលព្រៃឈើ។

**ប្រការ១០._**

រូបវន្តបុគ្គលឬនីតិបុគ្គលឯកជនដែលជាកម្មសិទ្ធិករដីធ្លី ដែលបង្កើតព្រៃឯកជនមានសិទ្ធិធ្វើការដាំដុះនូវប្រភេទឈើក្នុងស្រុកគ្រប់លំដាប់ថ្នាក់ ឬប្រភេទឈើក្រៅស្រុក ដែលមានអាយុប្រមូលផលខ្លីឬមធ្យម ជាប្រភេទឈើដែលធន់នឹងភាពប្រែប្រួលនៃលក្ខខណ្ឌប្រព័ន្ធមជ្ឈដ្ឋានមានតម្លៃសេដ្ឋកិច្ចខ្ពស់ និងមានតម្រូវការទីផ្សារក្នុងស្រុកឬក្រៅស្រុក។



M1.

ដើម្បីតម្រង់ទិសចំពោះកម្មសិទ្ធិករដីធ្លីក្នុងការជ្រើសរើសប្រភេទឈើសម្រាប់ដាំដុះបង្កើតព្រៃឯកជន រដ្ឋបាលព្រៃឈើត្រូវចេញនូវបញ្ជីប្រភេទឈើដែលត្រូវជ្រើសរើសសម្រាប់ចម្ការព្រៃដាំ ដោយបញ្ជាក់នូវព័ត៌មាននៃប្រភេទឈើនីមួយៗ ទាក់ទងទៅនឹងលក្ខខណ្ឌប្រព័ន្ធមជ្ឈដ្ឋានដូចជា៖ កត្តាដី សណ្ឋានភាពដី អាកាសធាតុ និងព័ត៌មានបច្ចេកទេសផ្សេងទៀតទាក់ទងទៅនឹងគ្រាប់ពូជ និងបច្ចេកទេសប្រព្រឹត្តកម្មគ្រាប់ពូជ។

**ប្រការ១១._**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មិនអនុញ្ញាតឱ្យកម្មសិទ្ធិករដីធ្លីបង្កើតព្រៃឯកជនដោយធ្វើការដាំដុះនូវប្រភេទឈើណាមួយ ដែលជាប្រភេទរាតត្បាត ឬប្រភេទចំណូលថ្មីឈ្លានពាន ដែលមានសក្តានុពលបង្កផលប៉ះពាល់ដល់កត្តាជីវសាស្ត្រនៃប្រភេទរុក្ខជាតិដើមក្នុងស្រុក ប្រព័ន្ធមជ្ឈដ្ឋាននៃចម្ការព្រៃដាំ ឬអាចរាតត្បាតដល់ដំណាំឈើហូបផ្លែ ដំណាំឧស្សាហកម្ម ឬដំណាំកសិកម្មផ្សេងទៀត។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិតម្រូវឱ្យកម្មសិទ្ធិករនៃព្រៃឯកជន បំផ្លាញចោលនូវផ្នែកណាមួយឬទាំងស្រុងនៃចម្ការព្រៃឯកជន ដែលបានដាំដុះប្រភេទឈើរាតត្បាត ឬប្រភេទចំណូលថ្មីឈ្លានពានដែលបានហាមឃាត់ក្រោមប្រការនេះ។

**ប្រការ១២._**

នៅពេលទទួលបានសេចក្តីរាយការណ៍ ឬពាក្យស្នើសុំចុះបញ្ជីព្រៃឯកជន រដ្ឋបាលព្រៃឈើមានសមត្ថកិច្ចត្រូវអនុវត្តការផ្តល់សេវាកម្មគាំទ្របច្ចេកទេស និងការតម្រង់ទិសផ្នែកបច្ចេកទេសដល់កម្មសិទ្ធិករដីធ្លីដែលស្នើសុំតាមរយៈការផ្តល់សេវាបណ្តុះបណ្តាលជំនាញបច្ចេកទេសដាំឈើ និងការគ្រប់គ្រងចម្ការព្រៃដាំ។

រដ្ឋបាលព្រៃឈើមានសមត្ថកិច្ចត្រូវចុះពិនិត្យ និងវាយតម្លៃជាក់ស្តែងលើទីតាំងស្នើសុំ ដើម្បីប្រមូលព័ត៌មាន និងទិន្នន័យមូលដ្ឋានសម្រាប់ការផ្តល់សេវាគាំទ្របច្ចេកទេស និងផ្តល់ការទទួលស្គាល់លើព្រៃឯកជនដែលស្នើសុំចុះបញ្ជី។

**ប្រការ១៣._**

ឆ្លងកាត់ដំណើរការផ្តល់សេវាកម្មគាំទ្របច្ចេកទេសរបស់រដ្ឋបាលព្រៃឈើមានសមត្ថកិច្ច នៅពេលដែលព្រៃឯកជនត្រូវបានដាំដុះរួច ដោយបង្កើតបានជាចម្ការព្រៃដាំពេញលក្ខណៈឬនៅក្នុងរយៈពេលមិនលើសពី០៣(បី)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទស្នើសុំចុះបញ្ជីព្រៃឯកជន រដ្ឋបាលព្រៃឈើមានសមត្ថកិច្ចត្រូវផ្តល់ជូនសិទ្ធិវន្តព្រៃឯកជននូវវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីព្រៃឯកជន ដោយគ្មានលក្ខខណ្ឌ ឬមិនតម្រូវឱ្យបង់កម្រៃសេវាសាធារណៈឡើយ។

វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីព្រៃឯកជនមានសុពលភាពនិរន្តរដោយគិតចាប់ពីកាលបរិច្ឆេទចេញវិញ្ញាបនបត្រ លើកលែងតែមានការដកហូតឬលុបចោលដោយរដ្ឋបាលព្រៃឈើ ដោយផ្អែកតាមមូលហេតុជាក់លាក់ណាមួយ។

រដ្ឋបាលព្រៃឈើមានសមត្ថកិច្ចត្រូវលុបចេញពីបញ្ជីព្រៃឯកជន ឬដកហូតវិញ្ញាបនបត្រ បញ្ជាក់ការចុះបញ្ជីព្រៃឯកជន ក្នុងករណីមានសំណើរបស់កម្មសិទ្ធិករព្រៃឯកជនស្នើសុំផ្ទេរការប្រើប្រាស់ដីកម្មសិទ្ធិរបស់ខ្លួន ក្នុងគោលបំណងផ្សេងទៀត។

ទម្រង់បែបបទសម្រាប់ការចុះបញ្ជីព្រៃឯកជន ត្រូវកំណត់ដោយរដ្ឋបាលព្រៃឈើ។

**ប្រការ១៤._**

ក្រោយពេលទទួលបានវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីព្រៃឯកជន សិទ្ធិវន្តព្រៃឯកជនសាមីត្រូវសម្របសម្រួល ឬសហការជាមួយមន្ត្រីជំនាញនៃរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចក្នុងការថែទាំចម្ការព្រៃដាំ និងគ្រប់គ្រងចម្ការព្រៃដាំរបស់ខ្លួន ដោយផ្អែកតាមបច្ចេកទេសរុក្ខវប្បកម្មដែលកំណត់ក្នុងផែនការដាំដុះបង្កើតព្រៃឯកជន ឬផែនការអភិវឌ្ឍព្រៃឯកជនសាមីរហូតដល់អាយុប្រមូលផល។



M1.

## ជំពូកទី៣
## ការប្រមូលផល និងការធ្វើអាជីវកម្មព្រៃឯកជន

**ប្រការ១៥._**

សិទ្ធិវន្តព្រៃឯកជនដែលបានចុះបញ្ជីព្រៃឯកជនរបស់ខ្លួនស្របតាមវិធាននៃប្រកាសនេះ មានសិទ្ធិក្នុងការប្រមូលផល ប្រើប្រាស់ និងធ្វើអាជីវកម្មផល អនុផលព្រៃឈើ និងផលិតផលឈើកែច្នៃ ដែលមានប្រភពចេញពីព្រៃឯកជនរបស់ខ្លួន ដោយគ្មានរបាំងប្បញ្ញត្តិ ឬការបង់កម្រៃសេវាសាធារណៈ លើកលែងតែការនាំចេញផលិតផលនៃព្រៃឯកជន។

**ប្រការ១៦._**

សិទ្ធិវន្តព្រៃឯកជននីមួយៗដែលបានចុះបញ្ជីព្រៃឯកជនស្របតាមវិធាននៃប្រកាសនេះមានភារកិច្ចទទួលខុសត្រូវកត់ត្រាចុះក្នុងសៀវភៅបន្ទុកព្រៃឯកជននូវរាល់សកម្មភាពក្នុងការប្រមូលផល និងការធ្វើអាជីវកម្មព្រៃឯកជនរបស់ខ្លួន រួមមានទិន្នន័យបរិមាណឈើប្រមូលផល ដឹកជញ្ជូន កែច្នៃ ធ្វើពាណិជ្ជកម្ម ឬប្រើប្រាស់។

គំរូសៀវភៅបន្ទុកព្រៃឯកជនត្រូវកំណត់ដោយរដ្ឋបាលព្រៃឈើ។

**ប្រការ១៧._**

នៅពេលចាប់ផ្តើមប្រតិបត្តិការប្រមូលផល សិទ្ធិវន្តព្រៃឯកជន ត្រូវកត់ត្រាក្នុងសៀវភៅបន្ទុកព្រៃឯកជនរបស់ខ្លួននូវទីតាំងឡូត៍ប្រមូលផល ទំហំផ្ទៃដីប្រមូលផល បរិមាណឈើឬផល អនុផលដែលបានប្រមូល និងដែលបានដឹកចេញពីចម្ការព្រៃឯកជនរបស់ខ្លួន សម្រាប់ការកែច្នៃ សម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និងសម្រាប់នាំចេញ។

រដ្ឋបាលព្រៃឈើមានសមត្ថកិច្ចនៃមូលដ្ឋានសាមីត្រូវគ្រប់គ្រងសំណុំឯកសារព្រៃឯកជននីមួយៗដែលបានចុះបញ្ជី និងមានសិទ្ធិត្រួតពិនិត្យសៀវភៅបន្ទុកព្រៃឯកជនណាមួយតាមការចាំបាច់ ឬក្នុងករណីសង្ស័យដើម្បីផ្ទៀងផ្ទាត់សកម្មភាពប្រមូលផលនិងការធ្វើអាជីវកម្មរបស់សិទ្ធិវន្តព្រៃឯកជននោះ។

**ប្រការ១៨._**

សិទ្ធិវន្តព្រៃឯកជនមានសិទ្ធិដឹកជញ្ជូនផល អនុផលព្រៃឯកជនរបស់ខ្លួនទៅកាន់ទិសដៅប្រើប្រាស់ ឬទៅកាន់ទីកន្លែងកែច្នៃក្នុងស្រុក ដោយពុំតម្រូវឱ្យស្នើសុំលិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើឡើយ។ សិទ្ធិវន្តព្រៃឯកជនត្រូវកត់ត្រាចុះក្នុងសៀវភៅបន្ទុកព្រៃឯកជនរបស់ខ្លួនអំពីទិន្នន័យដឹកជញ្ជូននេះ សម្រាប់ការត្រួតពិនិត្យរបស់អង្គភាពរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ក្នុងករណីចាំបាច់។

**ប្រការ១៩._**

សិទ្ធិវន្តព្រៃឯកជនមានសិទ្ធិកែច្នៃផល អនុផលព្រៃឯកជនរបស់ខ្លួនស្របតាមតម្រូវការទីផ្សារក្នុងស្រុក ឬក្រៅស្រុក។

ផល អនុផលព្រៃឯកជនអាចធ្វើការកែច្នៃនៅរោងកែច្នៃផល អនុផលព្រៃឈើដែលកាន់កាប់លិខិតអនុញ្ញាតជាធរមាន។

ការធ្វើអាជីវកម្មកែច្នៃផល អនុផលព្រៃឯកជន ត្រូវអនុលោមតាមបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ២០._**

សិទ្ធិវន្តបុគ្គលព្រៃឯកជនមានសិទ្ធិនាំចេញផល អនុផល ផលិតផលឈើកែច្នៃគ្រប់ប្រភេទដែលមានប្រភពចេញពីព្រៃឯកជនរបស់ខ្លួន។

ការនាំចេញផលិតផលព្រៃឯកជន ត្រូវមានអាជ្ញាប័ណ្ណនាំចេញដែលផ្តល់ដោយក្រសួងពាណិជ្ជកម្ម ដែលមានចុះទិដ្ឋាការដោយប្រធានរដ្ឋបាលព្រៃឈើ និងមិនតម្រូវឱ្យមានលិខិតអនុញ្ញាតដឹកជញ្ជូនផលិតផលដែលចេញដោយរដ្ឋបាលព្រៃឈើទៅកាន់មាត់ច្រកនាំចេញឡើយ។



ᩤ

ប្រតិបត្តិករដែលនាំចេញផលិតផលព្រៃឯកជន ត្រូវបង់កម្រៃសេវាបំពេញបែបបទនាំចេញចំនួន០១(មួយ) ភាគរយលើតម្លៃ FOB នៃផលិតផលសរុបនៅរដ្ឋបាលព្រៃឈើ និងពន្ធផ្សេងៗទៀតស្របតាមច្បាប់ជាធរមាន។

## ជំពូកទី៤
## អន្តរប្បញ្ញត្តិ

**ប្រការ២១.**_

រូបវន្តបុគ្គលឬនីតិបុគ្គលឯកជនដែលជាកម្មសិទ្ធិករដីធ្លី ដែលបានដាំឈើបង្កើតជាព្រៃឯកជន នៅមុនប្រកាសនេះចូលជាធរមាន ទោះមិនទាន់បានទទួល ឬបានទទួលស្គាល់តាមរយៈលិខិតបទដ្ឋានណាមួយក្តី ត្រូវស្នើសុំចុះបញ្ជីព្រៃឯកជនរបស់ខ្លួនស្របតាមវិធាននៃប្រកាសនេះ នៅក្នុងរយៈពេលមិនលើសពី០៦(ប្រាំមួយ)ខែ ដោយគិតចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃប្រកាសនេះ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**ប្រការ២២.**_

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២៣.**_

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេច អគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- ដូចប្រការ ២៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

លេខៈ ១៣៧៦ រព.នពជ

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម និងបញ្ជូនមក

លោកប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទរដ្ឋបាលព្រៃឈើ

" ដើម្បីជូនជ្រាប និងមុខការ "

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៧

ព. **ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលព្រៃឈើ**

**អនុប្រធាន**

**បណ្ឌិត កែវ អូម៉ាលីស្ស**